# ពិធីសារសម្រាប់ការវេចខ្ចប់ និងដឹកជញ្ជូនសំណាក
## (Specimen Packaging and Transport Protocol)







### ការប្រមូលយកសាកសពសត្វព្រៃដាក់ក្នុងថង់៖

***ត្រូវចងចាំថាត្រូវប្រើប្រាស់សម្ភារៈ PPE ជានិច្ចនៅពេលយកសាកសពសត្វព្រៃ***

1. ត្រឡប់ថង់ធំពីក្នុងចេញក្រៅពីលើដៃរបស់អ្នក
2. យកដៃចាប់យកសាកសពសត្វ បន្ទាប់មកត្រឡប់ថង់ច្រកសាកសពសត្វវិញ
3. បន្ធូរខ្យល់ដែលនៅសល់ក្នុងថង់ចេញឲ្យអស់ ប៉ុន្តែកុំឲ្យប៉ះពាល់ខ្លួនប្រាណយើង
4. ចងថង់ឲ្យជាប់ ក្របួចថង់ និងបិតស្កុតពីលើ ឬរូតបិទមាត់ថង់ឲ្យជាប់
5. អនុវត្តដំហាន ១ ដល់៤ ដើម្បីដាក់ថង់ទីមួយទៅក្នុងថង់ទី២មួយជាន់ទៀត

***បើមានសាកសពសត្វព្រៃច្រើន ត្រូវច្រកសាកសពសត្វនីមួយៗដាច់ដោយឡែកៗពីគ្នា***

### ការវេចខ្ចប់សំណាក៖

- ដាក់បំពង់យកសំណាកទាំងអស់នៅក្នុងថង់តូចមួយដោយដាក់សម្ភារៈរក្សាសំងួត (ដូចជា៖ សំឡី ឬក្រដាស់អនាម័យ) រួចចងថង់ឲ្យជិតល្អ
- បើពុំអាចដុតសម្លៀកបំពាក់ PPE ដែលបានប្រើប្រាស់រួចហើយបាននៅនឹងកន្លែងទេ ត្រូវច្រកវាទៅក្នុងថង់តូចមួយរួចចងមាត់ថង់ឲ្យជិត ។
- ដាក់ទម្រង់បែបបទកត់ត្រាអំពីហេតុការណ៍មានសត្វឈឺ/ងាប់នៅក្នុងថង់ដាក់សំណាកនោះ (ថង់ទី២) ឬអាចដាក់ទៅក្នុងថង់ទី៣មួយជាន់ទៀត រួចចងមាត់ថង់ឲ្យជាប់ ។

***ត្រូវជម្រាបជំនួយការអ្នកសម្របសម្រួល WHSN ជាមុនសិនអំពីករណីនេះដើម្បីសម្របសម្រួលការដឹកជញ្ជូនសំណាក***
***ត្រូវជម្រាបអ្នកត្រូវទទួលសំណាកនេះជាមុន អំពីពេលវេលាដែលគិតថាសំណាកនេះទៅដល់***

**ការរៀបចំប្រព័ន្ធត្រជាក់សម្រាប់សំណាក៖** ដាក់សំណាកទៅក្នុងទូទឹកកក/ធុងក្លាសេទឹកកកភ្លាមក្រោយពីប្រមូលយកសំណាកបានរហូតដល់ពេលរៀបចំការដឹកជញ្ជូនទៅកាន់មន្ទីរពិសោធន៍បានរួចរាល់ ។







1. ប្រើធុងស្នោរឹងរួចច្រងថង់ដាក់សម្រាមក្រាសមួយពីក្នុង
2. ដាក់ថង់សំណាកទៅក្នុងធុងទឹកកកនោះ រួចដាក់ទឹកកកពីលើ (ត្រូវប្រុងប្រយ័ត្នកុំឲ្យទឹកកកដែលរលាយនោះចូលក្នុងថង់ដាក់សំណាកបានឲ្យសោះ)
3. បិទស្កុតទប់ថង់ដាក់សំណាកឲ្យជាប់នៅខាងក្នុងកុំឲ្យក្រឡុក
4. គ្រប់ធុងទឹកកឲ្យជាប់រួចរុំស្កុតឲ្យជិត
5. សរសេរស្លាកពីលើធុងទឹកកកនោះនូវព័ត៌មានសម្រាប់ទំនាក់ទំនងអ្នកផ្ញើ និងអ្នកទទួល
6. បិទស្លាកសញ្ញា UN3373 ពីលើធុង




WCS